# សិល្បៈគំនូររឿងរាមកេរ្តិ៍នៅតាមវត្ត (ភាគ១)

ខ្មែរស្គាល់រឿងរាមកេរ្តិ៍យ៉ាងហោចប្រហែលជាងមួយសហសវត្សរ៍មកហើយ ដោយផ្អែកលើកស្តុតាងដំបូងគឺសិលាចារឹកវាលកន្ទេល(ខេត្តស្ទឹងត្រែង) ចារជាភាសាសំស្ក្រឹតក្នុងសតវត្សរ៍ទី៧ (ចុះលេខសារពើភណ្ឌK.359) និយាយពីគម្ពីររឿងរាមកេរ្តិ៍ និងកស្តុតាងមួយទៀតគឺចម្លាក់តួអង្គព្រះរាម មានការកំណត់កាលបរិច្ឆេទក្នុងសតវត្សរ៍ទី៧ រកឃើញនៅខេត្តតាកែវ។[1] ក្រៅពីនេះ គឺមានកស្តុតាងចម្លាក់រឿងរាមកេរ្តិ៍ឆ្លាក់បង្ហាញនៅតាមប្រាសាទ និងឈ្មោះតួអង្គរឿងរាមកេរ្តិ៍ជាច្រើន បានចារលើសិលាចារឹកសម័យអង្គរ (ស.វ.ទី៩-១២) ព្រមទាំងអត្ថបទសំណេរផ្សេងៗទៀតតាំងពីសតវត្សរ៍ទី១៥ និយាយពាក់ព័ន្ធរឿងរាមកេរ្តិ៍ ដូចជាសាស្ត្រាស្ទឹករឹត ក្រាំង អត្ថបទល្បើកអង្គរវត្ត ត្រៃភេទ-ត្រៃតាយុគ វេយាពណ៌សណ្ដំព្រះរាម និងបណ្ដាំពាលីជាដើម។ កស្តុតាងទាំងអម្បាលម៉ានខាងលើ ពិតជាមានឥទ្ធិពលតិច ឬច្រើនដល់ទំនៀមទម្លាប់ និងសិល្បៈផ្សេងៗទៀតក្នុងសង្គមខ្មែរ បូករួមទាំងសិល្បៈគំនូរនៅតាមវត្ត។

គំនូររឿងរាមកេរ្តិ៍លើសំណង់វត្តអារាមខ្មែរ ប្រហែលលេចឡើងតាំងពីចុងសតវត្សរ៍ទី១៩ ឬដើមសតវត្សរ៍ទី២០ ដែលគេយល់ថាចាប់ផ្ដើមនៅលើថែវព្រះវិហារព្រះកែវមរកតក្នុងព្រះបរមរាជវាំង។[2] ប៉ុន្តែក្រៅពីគំនូរលើថែវព្រះវិហារព្រះកែវមរកត គេឃើញមានព្រះវិហារមួយចំនួនទៀតនៅតាមតំបន់ផ្សេងៗ មានគំនូររឿងរាមកេរ្តិ៍ គូរបង្ហាញសាច់រឿងវែងអន្លាយច្រើនវគ្គ និងមានព្រះវិហារវត្តខ្លះ គូរបង្ហាញសាច់រឿងតែត្រង់អន្លើណាមួយ ឬគូរបង្ហាញតែតួអង្គមួយចំនួនតែប៉ុណ្ណោះ។[3] ក្នុងចំណោមនោះ គេឃើញថាខ្លះគឺជាព្រះវិហារបុរាណយូរអង្វែងមក ហើយខ្លះក៏ជាសំណង់ព្រះវិហារថ្មី កសាងក្នុងសម័យក្រោយដែរ។ អត្ថបទភាគ១នេះ ខ្ញុំសូមបង្ហាញទិដ្ឋភាពជារួមដោយត្រួសៗអំពីគំនូររឿងរាមកេរ្តិ៍នៅតាមព្រះវិហារមួយចំនួនដូចខាងក្រោម៖

---

[1] បញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌អរូបីកម្ពុជា, ២០១៧, ទំ.១២-១៥,

[2] *Danielle & Dominique-Pierre Guéret, 2017, p.54*

[3] រឿងរាមកេរ្តិ៍ ក្រៅពីគូរបង្ហាញក្នុងព្រះវិហារ ក៏សង្កេតឃើញមានគូរលើសំណង់ព្រះពុទ្ធសាសនាផ្សេងៗទៀតដែរ ហើយខ្លះក៏ខូចខាតបាត់បង់ទៅក្នុងសម័យសង្គ្រាម

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## ១.ថែវព្រះវិហារព្រះកែវមរកត

វត្តព្រះកែវមរកតសាងក្នុងរាជ្យ **ព្រះបាទនរោត្តម** (រូបលេខ១) ហើយព្រះវិហារសព្វថ្ងៃសាងជាថ្មីឡើងវិញក្នុងរាជ្យ **ព្រះករុណាព្រះបរមរតនកោដ្ឋ**។ ព្រះវិហារនេះព័ទ្ធដោយថែវជុំវិញប្រវែង៦៤២ម៉ែត្រមានគំនូររឿងរាមកេរ្តិ៍តាមជញ្ជាំងថែវទាំង៤ទិស (រូបលេខ២)។ បើយោងតាមឯកសារសំណេរ **ឧកញ៉ាវរវៀងជ័យ ជួន** គំនូររឿងរាមកេរ្តិ៍នៅថែវជុំវិញព្រះវិហារព្រះកែវមរកត១ចប់ មាន១៩២វគ្គ តែបើស្រង់ចំណាងជើងគំនូរមានរហូតដល់ចំនួន៥១១ចំណងជើង។[4] គំនូរទាំងនោះគូរតាមក្បួនខ្នាតគំនូរបុរាណ ជាស្នាដៃដឹកនាំរបស់**ឧកញ៉ាទេពនិម្មិត ម៉ក់** ហើយដែលគេសង្កេតសម្គាល់ឃើញជាពិសេសលើគំនូរ គឺការប្រើប្រាស់ពណ៌ជាអត្តសញ្ញាណតួអង្គនីមួយៗដូចជា ព្រះរាមប្រើពណ៌បៃតងដូចពណ៌ព្រះឥន្ទ្រ ព្រះលក្ស្មណ៍ពណ៌សាច់ឬខ្ចះហៅពណ៌ស្រី ហនុមានមានពណ៌ស អង្គទពណ៌បៃតងខ្ចីកាត់ខ្មៅឬបៃតងចាស់។



*រូបលេខ១-២ ព្រះវិហារព្រះកែវមរតក(ជ្រុងអាគ្នេយ៍)និងមួយផ្នែកថែវខាងក្រៅព្រះវិហារដែលគូររឿងរាមកេរ្តិ៍*

ចំពោះសាច់រឿងរាមកេរ្តិ៍លើថែវព្រះវិហារព្រះកែវមរកត លោកគូរចេញពីថែវខាងកើតវៀងព័ទ្ធទៅត្បូង ពោលគឺចាប់ពីអន្ទើ "នៅនគរអយុធ្យាមានស្តេចមួយអង្គព្រះនាមព្រះបាទទសរថ មានព្រះមហេសី៣អង្គ គឺនាងកោសូរីយា នាងកៃកេសី និងនាងទាវឡេក្ខា (នាងសមុទ្រាទេវី)។ មានបុត្រ៤អង្គ គឺព្រះរាម ដែលជាបុត្រមហេសីទី១ ព្រះលក្ស្មណ៍ ព្រះភិរុតជាបុត្រមហេសីទី២ និងព្រះសុត្រុត បុត្រមហេសីទី៣។ ព្រះរាជបុត្រទាំង៤អង្គនេះបានចេញទៅរៀនសិល្ប៍ជាមួយនឹងឥសី"(រូបលេខ៣) រហូតដល់ "ព្រះភិរុត ព្រះសុត្រុត

---

[4] *កក់ ច័ន្ទ ឋាត, ១៩៩៦: ៩៣-១៦១ និង សាគូ សាមុត, ២០០៧: ២៣-៥៤*

និងរាមលក្ស្មណ៍ ជបលក្ស្មណ៍ ព្រះបាទកៃយកេត លើកទ័ពទៅនគរអយុធ្យា ចូលគាល់ព្រះរាម ជួបជុំគ្នាមូលមីហើយ ព្រះរាមឲ្យព្រះភិរុត ព្រះសុត្រុត វិលទៅនគរកៃយកេតវិញ។ ឯសេនាទាំងឡាយក៏ទៅគ្រប់គ្រងនគររៀងៗខ្លួន។ ព្រះរាមនិងនាងសីតាបានរួបរួមនៅជាមួយគ្នា គ្រប់គ្រងនគរអយុធ្យាបានសុខក្សេមក្សាន្តជារៀងរហូតទៅ" (រូបលេខ២៤)។


រូបលេខ២៣ គំនូរផ្ដើមត្រង់អន្ទើ "នគរអយុធ្យា"


រូបលេខ២៤ គំនូរបញ្ចប់ត្រង់អន្ទើ "ចូលនគរអយុធ្យា"

ផ្ទៃរឿងត្រង់អន្ទើនានាជាទូទៅ លោកគូរបង្ហាញអំពីសង្គ្រាមរវាងព្រះរាម និងក្រុងរាពណ៍ ដោយមានព្រះលក្ស្មណ៍ ហនុមាន និងពលស្វា ប្រយុទ្ធជាមួយទ័ពយក្សយ៉ាងគគ្រឹកគគ្រេង ទាំងលើដី ក្នុងព្រៃភ្នំ សមុទ្រ និងលើអាកាស។ ទន្ទឹមនឹងនោះក៏មានអន្ទើខ្លះគូរពីដំណើររឿងភ្ជាប់នឹងចំណារខ្លីៗ ឬលោកគូរបញ្ចូលនូវកិច្ចពិធី ល្បែងរបាំ តូរ្យតន្ត្រី ផ្ទះអ្នកស្រុក ឬសំណង់ស្ថាបត្យកម្មផ្សេងៗយ៉ាងល្អវិចិត្រក្រៃលែង (រូបលេខ២៥-៦)។


រូបលេខ២៥ គំនូរត្រង់អន្ទើដែលរាពណ៍ប្រយុទ្ធនឹងព្រះរាម រួចក្រឡាខ្លួនជាព្រះព្រហ្មឲ្យព្រះរាមភ្លេចខ្លួន

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៦ គំនូរត្រង់អន្ទើព្រះរាមប្រឡងធ្នូ រួចរៀបអភិសេកនឹងព្រះនាងសេតានៅនគរមិថិឡា

## ២. ព្រះវិហារវត្តរាជបូព៌

ព្រះវិហារវត្តរាជបូព៌ កសាងឡើងក្នុងដើមសតវត្សរ៍ទី២០ ហើយជាព្រះវិហារដែលមានគំនូរបុរាណរឿងរាមកេរ្តិ៍ ស្ថិតនៅកណ្ដាលក្រុងសៀមរាប(រូបលេខ២៧)។ ព្រះវិហារនេះពុំមានគំនូរលើពិតានដូចព្រះវិហារដទៃឡើយ តែលើជញ្ជាំងជុំវិញមានគំនូររឿងរាមកេរ្តិ៍យ៉ាងល្អវិចិត្រជាច្រើនផ្ទាំង។ ជាទូទៅគំនូរក្នុងព្រះវិហារនេះ លោកគូរលើជញ្ជាំងខ្ពស់ទាំងបួនទិស ហើយអន្ទើនីមួយៗគូរក្នុងផ្ទៃតូចៗ ចែកសាច់រឿងតាមពណ៌ដែលលាបជាផ្ទៃគំនូរ ពុំដូចគំនូរលើថែវព្រះវិហារព្រះកែវមរកត (រូបលេខ២៨)។



រូបលេខ២៧ ព្រះវិហារវត្តរាជបូព៌ក្រោយជួសជុល



រូបលេខ២៨ មួយផ្នែកនៃគំនូរក្នុងព្រះវិហារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ការគូរសាច់រឿងរាមកេរ្តិ៍ក្នុងព្រះវិហារវត្តរាជបូព៌នេះ គេសង្កេតឃើញវិចិត្រករគូរតាមបែបគំនូរបុរាណ ហើយពិបាកនឹងកំណត់បានជាក់លាក់ថា ខ្លឹមសាររឿងចាប់ផ្តើមពីត្រឹមណា ហើយបញ្ចប់ត្រឹមណា។ ប៉ុន្តែក្នុងផ្ទៃគំនូររឿងរាមកេរ្តិ៍នៅព្រះវិហារនេះ គេសង្កេតឃើញគួរឱ្យកត់សម្គាល់ថា គឺវិចិត្រករបានបញ្ចូលទិដ្ឋភាពសួនឧទ្យាន ភូមិអ្នកស្រុក ផ្សារលក់ដូរជាតិសាសន៍ដទៃ ក្បួនទ័ព ព្រមទាំងគូរបញ្ចូលនូវវត្ថុប្រើប្រាស់ក្នុងសម័យថ្មីដូចជា នាឡិកាព្យួរជញ្ជាំង ឬចង្កៀងអគ្គិសនីក្នុងឈុតខ្លះ ស្រដៀងគំនូរនៅថែវព្រះវិហារព្រះកែវមរកត។ មិនតែប៉ុណ្ណោះលើជញ្ជាំងខាងជើង គឺមានអន្ទើមួយបង្ហាញពាក់ព័ន្ធទំនៀមកោរជុក(?) ឬអ្នកស្រុកខ្លះក្នុងតំបន់អង្គរហៅថាកោរកំប៉ោយ។ ត្រង់អន្ទើនោះ ឥសីបានរៀបចំធ្វើកិច្ចកោរសក់ឲ្យស្វាឈ្មោះ "អង្គទ" នៅលើបុស្បុក(រូបលេខ៩-១១)។ សូមបញ្ជាក់ថាទំនៀមកោរជុក ក្នុងភូមិមួយចំនួននៃតំបន់អង្គរនៅប្រតិបត្តិដល់សព្វថ្ងៃ។



រូបលេខ៩ ទិដ្ឋភាពឧទ្យាន



រូបលេខ១០ ទិដ្ឋភាពផ្សារ



រូបលេខ១១ នេះពិធីកោរសក់អង្គទ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

### ៣. ព្រះវិហារវត្តកំពង់ត្រឡាចលើ

វត្តកំពង់ត្រឡាចលើ ស្ថិតក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង គឺជាវត្តដែលមានព្រះវិហារបុរាណកសាងឡើងក្នុងដើមសតវត្សទី២០ដែរ។[5] ក្នុងឆ្នាំ២០២៥ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានជួសជុលរចនាសម្ព័ន្ធដំបូល និងគ្រឿងបង្គុំខាងលើនៃព្រះវិហារនេះរួចរាល់ជាស្ថាបពរ (រូបលេខ១១២)។ គំនូរជាទូទៅក្នុងព្រះវិហារ គឺជាប្រភេទគំនូរបុរាណដ៏ល្អវិចិត្រ លោកគូររឿងពុទ្ធប្រវត្តិ រឿងជាតកនានា និងអន្ទើ ឬតួអង្គខ្លះក្នុងរឿងរាមកេរ្តិ៍។



រូបលេខ១១២ ព្រះវិហារវត្តកំពង់ត្រឡាចលើក្រោយជួសជុល (រូបថត៖ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ)

អរិយធម៌ខ្មែរ KHMER CIVILIZATION

ពាក់ព័ន្ធរឿងរាមកេរ្តិ៍ក្នុងព្រះវិហារវត្តកំពង់ត្រឡាចលើ ហាក់មិនគូរជាសាច់រឿងវែងអន្លាយដូចថែវព្រះវិហារព្រះកែវមរកត ឬនៅព្រះវិហារវត្តរាជបូព៌ឡើយ។ លោកគូរបង្ហាញនៅលើពិតានត្រង់ចន្លោះល្វែងគ្រឹះ តួអង្គខ្លះទៀតគូរនៅត្រង់ហប់ខ្យល់ និងតាមគែមបង្អួច។ ក្នុងមួយផ្ទាំង គឺមានត្រឹមតែតួអង្គក្នុងរឿងរាមកេរ្តិ៍មួយ ឬពីរ ហើយគូរទំហំធំៗ ពុំមានសាច់រឿងប្រទាក់ក្រឡាគ្នាទេ (រូបលេខ១១៣-១១៦)។ តួអង្គនោះមានដូចជា ហនុមាន និងនាងមច្ឆា មេខលានិងរាមឥសូរ សុគ្រីពនិងពាលី និងតួអង្គគ្រុឌជាដើម។

---

[5] Daniel Guéret & Dominique-Pierre Guéret 2017: 177

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត






*រូបលេខ១៣-១៦ គំនូរតួអង្គខ្លះក្នុងរឿងរាមកេរ្តិ៍គូរលើពិតានព្រះវិហារវត្តកំពង់ត្រឡាចលើ*

*សង្ខេបសេចក្តីមក គំនូររឿងរាមកេរ្តិ៍នៅថែវព្រះវិហារព្រះកែវមរកត ព្រះវិហារវត្តរាជបូព៌ និងព្រះវិហារវត្តកំពង់ត្រឡាចលើ ពិតជាគំនូរបុរាណដ៏វិចិត្រនៃសិល្បៈខ្មែរ។ ប៉ុន្តែគំនូរនៅថែវព្រះវិហារព្រះកែវមរកត លោកគូរបង្ហាញលម្អិតសាច់រឿងវែងអន្លាយ។ រីឯគំនូរនៅព្រះវិហារវត្តរាជបូព៌ លោកព្យាយាមគូរបង្ហាញសាច់រឿងក្នុងផ្ទៃតូចៗ ដោយមានបញ្ចូលបន្ថែមទិដ្ឋភាពសង្គមជាក់ស្តែងច្រើន។ ចំណែកនៅព្រះវិហារវត្តកំពង់ត្រឡាច គឺពុំមានសាច់រឿងវែងឆ្ងាយឡើយ ពោលគឺលោកបង្ហាញតែតួអង្គខ្លះប៉ុណ្ណោះ៕*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

# ឯកសារយោង

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

២០១៧, *បញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌អរូបីកម្ពុជា*, ភ្នំពេញ

កក់ ច័ន្ទ ឋាត

១៩៩៦, *គំនូរបុរាណរឿងរាមកេរ្តិ៍នៅថែវព្រះវិហារព្រះកែវមរកត (ព្រះបរមរាជវាំង)*, មូលនិធិតូយូតា, ភ្នំពេញ

សាគូ សាមុត

២០០៧, *រឿងរាមកេរ្តិ៍*, បណ្ណាគារអង្គរ, ភ្នំពេញ

សាន ផល្លា

២០០៧, *គំនូរនៅតាមវត្ត*, រៃឃំ, ភ្នំពេញ

Danielle & Dominique-Pierre Guéret

2017, *The Khmer Pagoda*, KAM édition